# សៀវភៅផលិតកម្មពពែ

# ចំណី និង ការចិញ្ចឹមពពែ



បោះពុម្ពដោយ

**ហេហ្វឺ "គំរោងចិញ្ចឹមសត្វ" កម្ពុជា**

**Heifer Cambodia**

# សៀវភៅផលិតកម្មពពែ

# ចំណី និង ការចិញ្ចឹមពពែ

*បោះពុម្ពដោយ*

**ហេហ្វ៊ឺ"គំរោងចិញ្ចឹមសត្វ"កម្ពុជា**

**Heifer Cambodia**

ភ្នំពេញ

២០០៣

រក្សាសិទ្ធដោយ **ហេហ្វឺ“គំរោងចិញ្ចឹមសត្វ”កម្ពុជា** -**Heifer Cambodia**

បោះពុម្ពលើកទី ១: កុម្ភៈ ២០០៣

បោះពុម្ពដោយ **ហេហ្វឺ“គំរោងចិញ្ចឹមសត្វ”កម្ពុជា** - **Heifer Cambodia**

ផ្ទះលេខ ៧៧ $AE_0$ ផ្លូវ ៩៥ សង្កាត់បឹងកេងកង ៣ ខណ្ឌចំការមន ក្រុងភ្នំពេញ
Phone/Fax: (855-23) 211 323
Email: hpi.cambodia@online.com.kh

# **អារម្ភកថា**

ក្រោមគំនិតផ្តួចផ្តើម និង ការជ្រោមជ្រែងរបស់ លោក **សេន សុវណ្ណ** អនុប្រធាននាយកដ្ឋានផលិតកម្ម-បសុព្យាបាល និង ជាតំណាង HPI/Cambodia សៀវភៅផលិតកម្មពពែនេះ ត្រូវបានរៀបរៀងឡើងជាភាសាខ្មែរលើកដំបូង ដែលបានបកប្រែចេញពីសៀវភៅ “Sheep and Goat Production Handbook for Southeast Asia” ដោយខ្ញុំបាទ **ព្រាក់ សុចាំធី** ជំនួយការកម្មវិធី HPI/Cambodia និង កែសំរួលពាក្យពេចន៍ដោយ លោក **តែ គុយហោ** គ្រូបណ្តុះបណ្តាល HPI/Cambodia និង ដោយមានការគាំទ្រ និង ចូលរួមពីបុគ្គលិកទាំងអស់របស់ HPI/Cambodia ។

សៀវភៅបច្ចេកទេសនេះ បានត្រូវរៀបរៀងឡើងក្នុងគោលបំណងផ្តល់ជាមូលដ្ឋានចំណេះដឹងដល់សមាជិកគំរោង និង ដៃគូអនុវត្តនគំរោងរបស់ HPI/Cambodia និង សំរាប់កសិករទូទៅ អ្នកផ្សព្វផ្សាយ អ្នកស្រាវជ្រាវ ដែលពាក់ពន្ធ័ទៅនឹងការងារចិញ្ចឹមពពែ ដើម្បីចូលរួមចំណែកលើកស្ទួយផលិតកម្មពពែ បំរើអោយជីវភាពគ្រួសារ ។ សៀវភៅនេះ ក៏បានពន្យល់អំពីវិធីជ្រើសរើសពូជពពែ ការចិញ្ចឹម និង ការបង្កាត់ពូជពពែអោយបានទិន្នផលល្អប្រសើរផងដែរ ។

សៀវភៅនេះ ប្រាកដជាមានការខ្វះចន្លោះ ។ យើងខ្ញុំទាំងអស់គ្នារង់ចាំទទួលការរិះគន់កែលំអក្នុងន័យស្ថាបនាពីសំណាក់ លោក លោកស្រី អ្នកបច្ចេកទេស និង អ្នកពាក់ពន្ធ័ទាំងអស់ ។

យើងខ្ញុំទាំងអស់គ្នា ក៏សូមថ្លែងអំណរគុណផងដែរចំពោះ Roger C. Merkel និង Subandriyo ដែលជាអ្នកនិពន្ធសៀវភៅ “Sheep and Goat Production Handbook for Southeast Asia” ។

# មាតិកា


| | | |
|---|---|---|
| | អារម្ភកថា | ទំព័រ |
| I. | ចំណីអ្វីខ្លះសំរាប់ចិញ្ចឹមពពែ.................... | ១ |
| II. | ស្មៅ.................................. | ៤ |
| III. | រុក្ខជាតិផ្លែគួរ.............................. | ៦ |
| IV. | មែក-ស្លឹកឈើ............................ | ៨ |
| V. | អនុផលិតផល............................ | ១០ |
| VI. | ការផ្តល់អំបិល និង អំបិលខនិជ............. | ១២ |
| VII. | ទឹក.................................... | ១៦ |
| VIII. | ការពិចារណាលើទ្រុងសំរាប់ចិញ្ចឹមពពែ............ | ១៨ |
| IX. | ចំណីបន្ថែម............................ | ២០ |

## I. ចំណីអ្វីខ្លះសំរាប់ចិញ្ចឹមពពែ?

សត្វក៏ដូចជាមនុស្សដែរ ត្រូវការចំណីច្រើនប្រភេទសំរាប់ការរីកធំធាត់បានល្អ ។ ប្រសិនបើមនុស្សបរិភោគតែបាយ អ្នកនោះនឹងមានការរីកធំធាត់យឺត ។ ប្រសិនបើសត្វស៊ីតែស្មៅ វាក៏មានការរីកធំធាត់យឺតដែរ ។ មានចំណីច្រើនប្រភេទសំរាប់ចិញ្ចឹមសត្វឱ្យរីកធំធាត់លឿន ផ្តល់កូនដែលមានសុខភាពល្អ និង មានទឹកដោះច្រើនសំរាប់កូនវាបៅរីកធំធាត់ល្អ ។

**តើចំណីអ្វីខ្លះអាចផ្តល់ឱ្យពពែ?**

១- **ស្មៅ:** ស្មៅគឺជាផ្នែកដ៏សំខាន់នៃចំណីរបស់ពពែ ។ ពពែអាចស៊ីស្មៅដោយគេព្រលែងវាឱ្យស៊ីតាមវាល ឬ ច្រូតស្មៅឱ្យវាស៊ីនៅក្នុងក្រោល ។ ស្មៅផ្តល់ថាមពល ប្រូតេអ៊ីន និង អំបិលខនិជ (Mineral) ដល់សត្វ ។

២- **រុក្ខជាតិផ្លែគួរ (មានគ្រាប់តូចៗច្រើន):** រុក្ខជាតិផ្លែគួរត្រូវបានផ្តល់ឱ្យសត្វជាចំណីបន្ថែមដែលមានប្រូតេអ៊ីន និង អំបិលខនិជ សំរាប់ការលូតលាស់ និង ការផលិតកូន ឬ ការផលិតទឹកដោះ ។ ចំណីទាំងនេះអាចបានមកពីគ្រាប់ ឬ ស្លឹកដំណាំ ដូចជា សណ្តែក សណ្តែកដី ឬ សណ្តែកបារាំង ។

៣- **ស្លឹករុក្ខជាតិ:** ស្លឹករុក្ខជាតិខ្លះអាចផ្តល់ប្រូតេអ៊ីនដល់សត្វ ។ រុក្ខជាតិទាំងនេះ ងាយដាំ ហើយអាចផ្តល់ជាប្រភពយូរអង្វែងសំរាប់ចំណីសត្វ ។

៤- **អនុផលិតផល:** ចំណីអនុផលិតផលមានដូចជាកន្ទក់ ម្សៅដំឡូងមី ម្សៅសណ្តែកសៀង និង អនុផលផលិតផលផ្សេងៗទៀតជាច្រើន ដែលអាចផ្តល់ថាមពល និង ប្រូតេអ៊ីនដល់សត្វ ។ ជាទូទៅ ចំណីអនុផលិតផលមិនមានតំលៃថ្លៃប៉ុន្មានទេ ហើយមានអត្ថប្រយោជន៍ខ្លាំងណាស់ ប្រសិនបើ កសិករចង់ឱ្យសត្វរបស់ខ្លួនមានការរីកធំធាត់លឿន ។

៥- **កាកសំណល់អាហារក្នុងផ្ទះ** ចំណីដែលបានពីកាកសំណល់អាហារក្នុងផ្ទះ មានដូចជា សំបក និង ស្លឹកដំឡូងជ្វា ស្លឹកដំឡូងមីស្ងួត និង កាកសំណល់ផ្សេងៗទៀតដែល អាចផ្តល់ជាចំណី និង មានអត្ថប្រយោជន៍ចំពោះសត្វ ។

៦- **ធញ្ញជាតិ** ពពែអាចត្រូវបានចិញ្ចឹមដោយផ្តល់ធញ្ញជាតិជាចំណីដូចជា ល្ពៅ និង ពោត ។ សត្វដែលចិញ្ចឹមដោយឱ្យស៊ីចំណីទាំងនេះនឹងរីកធំធាត់បានល្អ ។ ប៉ុន្តែ ចំណីទាំងនេះមានតំលៃថ្លៃ ហើយមិនផ្តល់ការចំនេញក្នុងការប្រើប្រាស់ជាចំណីសត្វ ។

៧- **អំបិលខនិជ** សត្វក៏ត្រូវការអំបិល និង អំបិលខនិជក្នុងចំណីរបស់វា ដើម្បីឱ្យវា រីកលូតលាស់បានល្អ ។ អំបិលធម្មតា ថ្មកំបោរ និង អំបិលខនិជចំរុះ អាចផ្តល់ឱ្យ សត្វស៊ីក្នុងចំនួនតិចតួច ។

៨- **ទឹក** ទឹកមានសារៈសំខាន់សំរាប់សត្វ ដូចគ្នាទៅនឹងមនុស្សដែរ ។ សត្វខ្លះត្រូវការ ទឹកច្រើនជាងសត្វដទៃទៀត ដូចជា មេពពែក្នុងការផលិតទឹកដោះ ។

## ចំណីអ្វីខ្លះសំរាប់ចិញ្ចឹមពពែ



## II. ស្មៅ

ពពែត្រូវការស្មៅច្រើនជាងចំណីដទៃទៀត ។ មានមធ្យោបាយពីរដែលសត្វអាចទទួលស្មៅជាចំណី គឺ ការលែងសត្វឱ្យស៊ីតាមទីវាល និង ការច្រូតស្មៅឱ្យសត្វស៊ីក្នុងក្រោល ។

### ១- ការលែងសត្វឱ្យស៊ីស្មៅតាមវាល

⇨ សត្វគួរតែត្រូវបានលែងតាមវាលឱ្យស៊ីស្មៅឱ្យបានយូរ តាមដែលអាចធ្វើទៅបាន ។ យ៉ាងហោចណាស់ ពពែត្រូវលែងតាំងពីព្រលឹមរហូតដល់ក្រោយថ្ងៃត្រង់ (៨ម៉ោង ឬ ច្រើនជាងនេះ) ដើម្បីស៊ីស្មៅតាមវាល ហើយចំណីបន្ថែម (ស្មៅ ឬ ស្លឹកឈើ) ត្រូវផ្តល់ឱ្យវាជាបន្ថែម ។

⇨ វាលស្មៅត្រូវមានស្មៅគ្រប់គ្រាន់ដើម្បីឱ្យសត្វស៊ី ។

⇨ ពពែត្រូវការអ្នកឃ្វាល ដើម្បីការពារកុំឱ្យចោរលួច ឆ្កែខាំ ឬ បាត់បង់ ។

### ២- ការច្រូតស្មៅ និង ដឹកជញ្ជូនស្មៅឱ្យសត្វស៊ី

ចំពោះសត្វចិញ្ចឹមក្នុងទ្រុង និង សត្វដែលត្រូវបានព្រលែងឱ្យស៊ីស្មៅតាមវាលតែ ៤ម៉ោង ឬ ៥ម៉ោង ក្នុងមួយថ្ងៃ ស្មៅត្រូវបានច្រូតដើម្បីផ្តល់ជាចំណីដល់សត្វទាំងនោះ ។

⇨ ត្រូវជ្រើសរើសស្មៅនៅខ្ចីដើម្បីច្រូត ។ ស្មៅត្រូវមានពណ៌បៃតង ហើយមិនមានផ្កា ឬ មិនមានគ្រាប់ ។ ស្មៅខ្ចីមានលក្ខណៈល្អប្រសើរសំរាប់សត្វជាងស្មៅចាស់ ។

⇨ ត្រូវច្រូតស្មៅ ឬ កាត់រុក្ខជាតិផ្លែគួរ ក្រោយថ្ងៃត្រង់ ។ ការធ្វើរបៀបនេះ គឺដើម្បីជួយកាត់បន្ថយចំនួនដង្កូវ និង ពងដង្កូវឱ្យនៅទាប ។

⇨ ត្រូវច្រូតស្មៅលាយគ្នានឹងការកាប់មែក-ស្លឹកឈើដាក់ឱ្យសត្វស៊ី ។ ពពែជាសត្វស៊ីរើស ហើយការមានចំណីច្រើនបែប នឹងងាយស្រួលឱ្យវាជ្រើសរើសចំណីណាដែលវាចង់ស៊ី ។

⇨ ស្លឹកឈើគួរតែត្រូវបានច្រូតកាត់ ដើម្បីផ្តល់ជាចំណីសត្វ ។

⇨ ត្រូវផ្តល់ចំណីដល់ពពែឱ្យបានច្រើនបំផុតតាមតែវាចង់ស៊ី ។

## ស្មៅ

ក- ការលែងសត្វឱ្យស៊ីស្មៅតាមវាល

- ពពែគួរតែត្រូវបានព្រលែងឱ្យស៊ីស្មៅតាមវាលអោយបានយូរក្នុង មួយថ្ងៃៗ





ខ- ការច្រូតស្មៅ និង ដឹកជញ្ជូនស្មៅឱ្យសត្វស៊ី

- ត្រូវច្រូតស្មៅក្រោយថ្ងៃត្រង់ ក្រោយពីទឹកសន្សើមស្ងួត
- ត្រូវជ្រើសរើសស្មៅមិនទាន់ចេញផ្កា ដើម្បីច្រូត
- ត្រូវច្រូតស្លឹកស្មៅអោយបានច្រើនជាងដើមស្មៅ

## III. រុក្ខជាតិផ្លែគួរ

រុក្ខជាតិផ្លែគួរត្រូវបានផ្តល់ជាចំណីពពែដើម្បីផ្តល់ប្រូតេអ៊ីនសំរាប់ការលូតលាស់ និង ផលិតកម្ម ។ ជាទូទៅ រុក្ខជាតិផ្លែគួរ គឺជារុក្ខជាតិដែលមានផ្លែជាគួរដោយមានគ្រាប់ច្រើន ដូចសណ្តែក ឬ សណ្តែកបារាំង ។ សណ្តែកដី ក៏ជារុក្ខជាតិផ្លែគួរដែរ ។

- ⇨ ត្រូវច្រូតកាត់រុក្ខជាតិផ្លែគួរពេលវានៅខ្ចី ហើយផ្តល់ជាចំណីដល់សត្វដោយលាយវាជាមួយស្មៅ ។
- ⇨ រុក្ខជាតិផ្លែគួរអាចដាំលាយចំរុះជាមួយស្មៅ ។
- ⇨ បរិមាណរុក្ខជាតិផ្លែគួរដែលផ្តល់ជាចំណីសត្វ អាស្រ័យទៅលើសត្វ និង ប្រភេទផលិតកម្ម ។ សត្វជើម និង សត្វកំពុងបំបៅកូន ត្រូវការរុក្ខជាតិផ្លែគួរច្រើនជាងសត្វឈ្មោល ។ ករណីនេះ គឺដោយសារថា សត្វញីផលិតកូន និង ទឹកដោះ។ សត្វតូចៗក៏ត្រូវការចំណីរុក្ខជាតិផ្លែគួរច្រើន ពីព្រោះ វាត្រូវការការលូតលាស់ ។

## រុក្ខជាតិផ្លែគួរ

- ត្រូវផ្តល់រុក្ខជាតិផ្លែគួរជាចំណីសត្វដោយលាយជាមួយស្មៅ
- ត្រូវច្រូតកាត់រុក្ខជាតិផ្លែគួរពេលវានៅខ្ចី



សណ្តែកគួរ



សណ្តែកបាយ



សណ្តែកបារាំង



សណ្តែកសៀង





សណ្តែកដី

## IV. មែក-ស្លឹកឈើ

ដើមឈើខ្លះក៏ជារុក្ខជាតិមានផ្លែគួរដែរ ហើយផ្តល់ស្លឹកជាចំណីពពែដែលជាប្រភពប្រូតេអ៊ីនមួយដ៏ល្អ ។ ឧទាហរណ៍ខ្លះៗនៃរុក្ខជាតិទាំងនោះ គឺ ដើមកន្ធំថេត ដើមអង្គារដី ។ល។

⇨ សត្វអាចស៊ីស្លឹក និង មែកតូចៗរបស់រុក្ខជាតិទាំងនោះ ។

⇨ ស្លឹកឈើអាចយកមកជំនួសរុក្ខជាតិផ្លែគួរ (ពពួកសណ្តែក) ។ ត្រូវផ្តល់ស្លឹកឈើឱ្យសត្វស៊ី មិនលើសពី ៣០% នៃ ចំណី ឬ ស្មៅ ។

⇨ ត្រូវកាត់មែកឈើកំពស់មួយម៉ែត្រពីដី ហើយដាក់មែកឈើតូចៗទៅក្នុងស្នូកចំណី ឬចងព្យួរក្នុងក្រោលឱ្យសត្វស៊ី ។ ពពែចូលចិត្តស៊ីចំណីដែលព្យួរផុតពីដីដើម្បីងាយស្រួលវាជ្រើសរើស ។

⇨ ដូចរុក្ខជាតិផ្លែគួរដទៃទៀតដែរ សត្វជើម សត្វមានកូន ឬ សត្វកំពុងលូតលាស់ត្រូវការស្លឹកឈើច្រើនជាងសត្វពេញវ័យ ។

⇨ រុក្ខជាតិជាចំណើសត្វ អាចដាំតាមរបងជុំវិញផ្ទះ ឬ ក្រោលសត្វ ដោយដាក់ជីកំប៉ុសលាមកសត្វ ។

⇨ ត្រូវជ្រើសរើសពូជរុក្ខជាតិណាដើម្បីដាំ អាស្រ័យលើសណ្ឋានដី និង អាកាសធាតុ និង ប្រភេទដំណាំ ។

## ស្លឹក -មែករុក្ខជាតិ



- ត្រូវកាត់មែកឈើកំពស់មួយម៉ែត្រពីដី



- មែកឈើត្រូវបានចងជាបាច់ និង ព្យួរក្នុងទ្រុងឱ្យសត្វស៊ី
- ពពែនឹងធ្វើការជ្រើសរើសស្លឹកឈើណាដែលវាចង់ស៊ី

## VI. ការផ្តល់អំបិល និង អំបិលខនិជ

ពពែត្រូវការអំបិល និង អំបិលខនិជ ដើម្បីរីកលូតលាស់ និង សំរាប់បង្កើនភាពឆ្ងាញ់ (Appetite) របស់វា ។

មានមធ្យោបាយជាច្រើនក្នុងការផ្តល់អំបិល ឬ អំបិលខនិជជាចំណើសត្វៈ

### ក- ដាក់អំបិលក្នុងបំពង់ឫស្សីឱ្យសត្វលិត

ក្នុងមធ្យោបាយនេះ អំបិលនឹងមិនត្រូវបានខ្ជះខ្ជាយ ហើយសត្វអាចលិតបំពង់ឫស្សីនៅពេលដែលវាត្រូវការអំបិល ។

**វិធីធ្វើបំពង់ឫស្សីដាក់អំបិលឱ្យសត្វលិតៈ**

⇨ ជ្រើសរើសបំពង់ឫស្សីធំ ( អង្កត់ផ្ចិតពី ៦ ទៅ ៩ ស.ម )

⇨ កាត់បំពង់ឫស្សីប្រវែងមួយថ្នាំងកន្លះ ( មើលរូប )

⇨ សកសំបកស្រទាប់ក្រៅបំពង់ឫស្សី ( មើលរូប )

⇨ ចោះមាត់បំពង់ ដាក់ដៃយួរ ដើម្បីងាយស្រួលក្នុងការព្យួរវាទៅក្នុងក្រោល

⇨ ចាក់អំបិល និង អំបិលខនិជចំរុះ និង ចាក់ទឹកបន្តិចចូលក្នុងបំពង់ឫស្សី

⇨ ព្យួរបំពង់ឫស្សីនៅកាច់ជ្រុងក្រោលកំពស់ ៧៥-១០០ ស.ម ពីកម្រាលទ្រុង ។

### ខ- ដាក់អំបិលក្នុងកូនធុងជ័រតូច ហើយចងភ្ជាប់ធុងជ័រនោះទៅនឹងជ្រុងជញ្ជាំងខាងក្នុងក្រោល ដើម្បីឱ្យសត្វលិត ។

## ការផ្តល់អំបិល និង អំបិលខនិជ

ក- ដាក់អំបិលក្នុងបំពង់ឫស្សីអោយសត្វលិត




- *ការធ្វើបំពង់ឫស្សីដាក់អំបិលឱ្យសត្វលិត*




ខ- ដាក់អំបិលក្នុងកូនធុងជ័រ



ដាក់អំបិលក្នុងកូនធុងជ័រ ហើយចងភ្ជាប់ធុងជ័រនោះទៅនឹងជ្រុងជញ្ជាំងខាងក្នុងក្រោល

### គ- ការធ្វើជុំអំបិល ឬ អំបិលខនិជ និង ព្យួរវាក្នុងទ្រុង

ជុំអំបិល ឬ អំបិលខនិជអាចឱ្យសត្វលិត និង អាចឱ្យសត្វទទួលបានអំបិលពេលណាវាត្រូវការ ។ ជុំអំបិលនេះ អាចត្រូវបានប្រើប្រាស់ក្នុងរយៈពេលវែង ហើយជាមធ្យោបាយដ៏មានប្រសិទ្ធភាពមួយ ក្នុងការផ្តល់អំបិលខនិជទៅឱ្យសត្វ ។

**សំភារៈសំរាប់ធ្វើជុំអំបិលខនិជមាន:**

- អំបិលខនិជចំរុះ (១ គ.ក្រ)
- អំបិលធម្មតា ៣,៤៥ គ.ក្រ
- ស៊ីម៉ង់ត៍ ០,៥៥ គ.ក្រ
- ទឹក
- ធុងប្លាស្ទិច (ធុងជ័រ) តូចចំណុះ ៤-៥ លីត្រ
- ដែកលួសរឹងមាំ សំរាប់ដាក់ក្នុងជុំអំបិល ដើម្បីអាចព្យួរវាក្នុងក្រោលក្រោយពេលជុំអំបិលរឹង ។
- ថង់ប្លាស្ទិច
- ធុងធំសំរាប់លាយ

**វិធីធ្វើ:**

⇨ ដាក់ថង់ប្លាស្ទិចចូលក្នុងធុងជ័រ ដើម្បីងាយស្រួលក្នុងការយកជុំអំបិលចេញពេលវារឹង ។

⇨ ប្រើដែកលួសប្រវែង ៤០ ស.ម ហើយពុតជាទំពួកចុងទាំងសងខាង (មើលរូប) ។

⇨ ដាក់ស៊ីម៉ង់ត៍ក្នុងធុងធំហើយលាយទឹកបន្តិច។ ដាក់បន្ថែមម្សៅអំបិលខនិជចំរុះ និង អំបិលទៅក្នុងធុងធំ ។

⇨ ដាក់ដែកលួសចូលក្នុងធុងល្បាយឱ្យដល់បាតធុង ។

⇨ ដាក់ធុងល្បាយនៅកន្លែងសមរម្យ កុំឱ្យត្រូវភ្លៀង និង កុំឱ្យស្លឹកឈើជ្រុះលើ ចំនួន៤ថ្ងៃទំរាំវាស្ងួត ។

⇨ ក្រោយពេលស្ងួតត្រូវយកថង់ប្លាស្ទិចចេញពីជុំអំបិល ហើយព្យួរវានៅក្នុងទ្រុងកំពស់មួយជំហរសត្វតូចជាងគេ ។

## គ- ការធ្វើដុំអំបិល ឬ អំបិលខនិច និង ព្យួរវាក្នុងក្រោល




- ដាក់ស៊ីម៉ង់ត៍ ០.៥៥ គ.ក្រ និង ទឹកបន្តិច ចូលក្នុងធុងធំ ហើយច្របល់ចូលគ្នា
- បន្ទាប់មក ដាក់បន្ថែមអំបិល ៣.៤៥ គ.ក្រ និង អំបិលខនិចចម្រុះ ១ គ.ក្រ





- ចាក់ល្បាយអំបិលចូលក្នុងធុងតូច ដែលមានទ្រាប់ថង់ប្លាស្ទិច
- ដាក់ដែកលួសដែលចុងសងខាងមាន ពុតជារាងទំពក់ ចូលក្នុងធុងល្បាយ
- ទុកល្បាយអោយស្ងួតដោយ ការពារកុំអោយត្រូវភ្លៀង

- យកដុំល្បាយអំបិលស្ងួតចេញពីធុង ហើយព្យួរវានៅក្នុងទ្រុងកំពស់មួយជិតហរសត្វតូចជាងគេ

## VII. ទឹក

រាងកាយសត្វផ្សំឡើងពីទឹកចំនួន ៧០% ។ ប្រសិនបើសត្វបាត់បង់ជាតិទឹកចំនួន ២០% នៃទឹកក្នុងរាងកាយ វានឹងបណ្តាលឱ្យសត្វស្លាប់ ។ ទឹកមានសារៈសំខាន់សំរាប់រាល់ដំណើរការជីវិត រួមទាំងការរំលាយអាហារ ។ វាជាការចាំបាច់ណាស់ ដែលត្រូវតែមានទឹកគ្រប់ពេលវេលា ។

បរិមាណទឹកដែលសត្វត្រូវការ ប្រែប្រួលអាស្រ័យលើ:

- សភាពនៃសរីរៈរបស់សត្វ-សត្វតូចត្រូវការទឹកច្រើនជាងសត្វពេញវ័យ សត្វបំបៅកូនត្រូវការទឹកច្រើនជាងសត្វមិនបំបៅកូន ។
- សត្វដែលគេផ្តល់ចំណីចាស់ ឬ ចំណីធម្មជាតិ ត្រូវការទឹកច្រើនជាងសត្វដែលគេផ្តល់ចំណីខ្ចី ។

ពពែត្រូវការទឹកជាមធ្យមពី ១.៥ ទៅ២.៥ លីត្រ/ថ្ងៃ ។ ទឹកផឹកត្រូវតែស្អាត ហើយស្នូកទឹកត្រូវតែសំអាត រៀងរាល់ ២ថ្ងៃម្តង ។

**ស្នូកទឹក**

ស្នូកទឹកអាចទិញ ឬ ធ្វើដោយកសិករផ្ទាល់ ។ ឧទាហរណ៍នៃការធ្វើស្នូកទឹក មានដូចខាងក្រោម:

**ក- ធុងជ័រ**

⇨ ត្រូវដាក់ជិតស្នូកចំណី

⇨ នៅក្នុងក្រោល ត្រូវដាក់វានៅកន្លែងណាដែលវាមិនអាចដួលកម្ពប់ ។

**ខ- ស្នូកទឹកធ្វើពីឈើ**

⇨ ទំហំស្នូកទឹកអាស្រ័យលើចំនួនសត្វ

⇨ ពន្ទះក្តារត្រូវជិតភ្ជាប់គ្នា ហើយលាបពណ៌ខ្មៅដើម្បីប្រើប្រាស់បានយូរ

⇨ ត្រូវដាក់ស្នូកទឹកជិតស្នូកចំណី ហើយមិនត្រូវឱ្យវាដួលកម្ពប់ ឬ ធ្វើឱ្យកខ្វក់

**គ- ស្នូកទឹកធ្វើពីបំពង់ឫស្សីធំៗ**

⇨ បំពង់ឫស្សីដែលយកមកប្រើ ត្រូវមានទំហំធំ

⇨ ប្រវែងស្នូកទឹក អាស្រ័យលើទំហំក្រោល ឬ ចំនួនសត្វ

⇨ ស្នូកទឹក ត្រូវដាក់នៅផ្នែកខាងក្រោយក្រោល ។

## ស្នូកទឹក

ក- ធុងជ័រ







ខ- ស្នូកទឹកធ្វើអំពីបន្ទះក្តារក្រាស់ (កំរាស់ ១៣ ស.ម)







គ- ស្នូកទឹកធ្វើអំពីបំពង់ឬស្សីធំ






ដាក់ស្នូកទឹកនៅផ្នែកខាងក្រោយទ្រុង

## VIII. ការពិចារណាលើទ្រូងសំរាប់ការចិញ្ចឹមពពែ

តំរូវការចំណីសំរាប់ពពែ មានលក្ខណៈខុសៗគ្នាពីសត្វមួយទៅសត្វមួយដោយអាស្រ័យទៅលើលក្ខណៈសរីរៈរបស់វា ដូចជា មេដើម ឬ មេបំបៅកូន មេជំទង់ ឬ មេមិនទាន់ដើម សត្វឈ្មោលពេញវ័យ និង កូនពពែកំពុងរីកលូតលាស់លឿន ។ ពពែគួរត្រូវបានចិញ្ចឹមអាស្រ័យលើលក្ខណៈរបស់វា ហើយដើម្បីធ្វើដូចនេះបាន សត្វត្រូវបានដាក់ឱ្យនៅក្នុងទ្រុងដាច់ដោយឡែកពីគ្នា ។

ការដាក់សត្វក្នុងទ្រុង គឺអាស្រ័យទៅលើ ភេទ អាយុ និង លក្ខណៈសរីរៈរបស់សត្វ។

ឧទាហរណ៍:

- មេដើម និង មេមានកូន
- មេជំទង់មុនពេលអាយុចាស់គ្រប់គ្រាន់សំរាប់បង្កាត់
- សត្វឈ្មោលពេញវ័យ
- កូនពពែផ្ដាច់ដោះ

ការដាក់សត្វក្នុងទ្រុងដោយឡែកពីគ្នា គឺជាការចាំបាច់ដើម្បីកុំឱ្យសត្វដណ្ដើមគ្នាស៊ីចំណី ។ ឧទាហរណ៍ ប្រសិនបើសត្វឈ្មោលពេញវ័យត្រូវបានដាក់ក្នុងទ្រុងជាមួយសត្វមេដែលមានកូន នោះសត្វឈ្មោលពេញវ័យនឹងរុញ (ជុល) កូនពពែ មិនឱ្យចូលស៊ីចំណី ។ កូនពពែនឹងមិនទទួលបានចំណីគ្រប់គ្រាន់ ហើយនឹងមានការរីកលូតលាស់យឺត ។ កូនពពែទាំងនោះ ក៏អាចនឹងរងរបួសដោយសារសត្វឈ្មោល ឬ ក៏អាចក្លាយជាមានជំងឺ ។

## ការពិចារណាលើទ្រុងសំរាប់ការចិញ្ចឹមពពែ



ការដាក់ស្នូកចំណីមិនត្រឹមត្រូវ
ដែលនាំឱ្យសត្វដណ្ដើមគ្នាស៊ីចំណី



ការដាក់សត្វក្នុងទ្រុងត្រឹមត្រូវ

- ការដាក់ក្រុមសត្វដោយឡែកពីគ្នា



## IX. ចំណីបន្ថែម

អាហារបន្ថែមត្រូវបានផ្តល់ឱ្យសត្វជាបន្ថែមលើចំណី ហើយមានជីវជាតិដែលមិនអាចរកបាននៅក្នុងចំណីនោះ ។ អាហារបន្ថែមផ្តល់ថាមពល និង ប្រូតេអ៊ីនបន្ថែមចំពោះសត្វដែលត្រូវការវា ។ សត្វទាំងនោះអាចជា ពពែមេដែលក្រដើម ឬ ផ្តល់ទឹកដោះតិច ។ កូនពពែជំទង់ត្រូវការចំណីខ្លះ ដើម្បីឱ្យវាសាំក្នុងការស៊ីចំណីលាយ (Concentrate) ហើយជួយវាឱ្យរីកលូតលាស់បានល្អនៅពេលវាផ្តាច់ដោះ ។ កូនសត្វផ្តាច់ដោះ ឬ កូនសត្វជំទង់ដែលកសិករចង់បំប៉នវាសំរាប់យកទៅលក់នៅទីផ្សារ ក៏ត្រូវការចំណីបន្ថែមដើម្បីឱ្យវាធំធាត់ឆាប់រហ័សដែរ ។ សំរាប់ចំណីបន្ថែមដែលបង្ហាញពី ផលចំណេញយ៉ាងសន្ធឹកសន្ធាប់ សត្វត្រូវមានសុខភាពល្អ និង ត្រូវបានគ្រប់គ្រងបានយ៉ាងល្អ ។ សត្វឈឺ ឬ សត្វដែលមានព្រូនក្នុងខ្លួននឹងមិនអាចរីកលូតលាស់បានល្អឡើយ ទោះបីជាផ្តល់ចំណីដែលមានគុណភាពខ្ពស់ឱ្យវាក៏ដោយ ។

ចំណីបន្ថែមអាចជារុក្ខជាតិផ្លែគួរ ចំណីតែមួយមុខ ឬ ចំណីបន្ថែមចំរុះដែលប្រើប្រាស់ធាតុផ្សំជាច្រើន ដូចដែលបានពិភាក្សារួចមកហើយនៅក្នុងផ្នែកអនុផលិតផល ។ អនុផលិតផលកសិផល ដូចជា ស្លឹកដំឡូងមី (ដំឡូងឈើ) ក៏អាចប្រើប្រាស់ជាចំណីបន្ថែមបានដែរ ។

- ⇨ **កន្ទក់:** ត្រូវបានផ្តល់ជាចំណីបន្ថែមដល់មេដើម និង មេបំបៅកូន ។ ការផ្តល់កន្ទក់ពីមួយទៅពីរក្តាប់ សំរាប់សត្វមួយក្បាលក្នុងមួយថ្ងៃ អាចផ្តល់ថាមពលបន្ថែមដល់សត្វ ។ នៅពេលដែលផ្តល់កន្ទក់ ត្រូវលាយថ្មកំបោរ (Limestone) ជាមួយកន្ទក់សំរាប់ឱ្យសត្វស៊ី ។ សំរាប់ធុងកន្ទក់ចំណុះ ៥ លីត្រ ត្រូវបន្ថែមថ្មកំបោរ និង អំបិលមួយក្តាប់ ។ កន្ទក់មានបរិមាណអំបិលផូស្វ័រខ្ពស់ ។ ប្រសិនបើផ្តល់បរិមាណកន្ទក់ច្រើនដល់កូនពពែឈ្មោលដោយមិនលាយជាមួយថ្មកំបោរ នោះគ្រោះក្នុងតំរងនោមអាចនឹងរីកធំឡើង ។

⇨ **ម្សៅគ្រាប់កៅស៊ូៈ** ត្រូវបានផ្តល់ជាចំណីបន្ថែមដោយលាយជាមួយស្លឹកឈើ (ដូចជាស្លឹកដំឡូង ស្លឹកកន្ទុំថេត) ក្នុងចំនួនស្មើគ្នា ។ ម្សៅគ្រាប់កៅស៊ូ ក៏អាចលាយជាមួយចំណីលាយផងដែរ ។ ជាឧទាហរណ៍ គេអាចផ្តល់ឱ្យសត្វនូវបរិមាណស្មើគ្នានៃម្សៅគ្រាប់កៅស៊ូ និង ចំណីលាយ (កន្ទក់ ៤ គ.ក្រ ម្សៅដំឡូងមី ៣ គ.ក្រ ម្សៅត្រី ១០០ក្រ. ជីអ៊ុយរេ ១០០ក្រ. ថ្មកំបោរ ១៥០ក្រ.) ។

⇨ **ស្លឹកដំឡូងមីៈ** ស្លឹកដំឡូងមីអាចបេះពីផ្នែកខាងក្រោមនៃដើមដំឡូង ក្រោយពេលដែលដើមដំឡូងមានអាយុ ៤ខែ ។ បន្ទាប់ពីការបេះស្លឹកលើកទីមួយ ត្រូវទុកដើមដំឡូងឱ្យនៅទំនេរក្នុងរយៈពេល មួយសប្តាហ៍ មុនពេលបេះស្លឹកវាជាលើកទី២ ។ ត្រូវហាលស្លឹកដំឡូងចំនួនមួយថ្ងៃមុនពេលផ្សំជាចំណីដើម្បីបំបាត់បន្សំជាតិពុល ។ ស្លឹកដំឡូងមី គឺជាប្រភពប្រូតេអ៊ីន ហើយអាចលាយជាមួយចំណីបន្ថែមដទៃទៀត ដូចជាកន្ទក់ ដើម្បីផ្តល់ថាមពលបន្ថែម ។ ស្លឹកដំឡូងមីអាចមានជាតិពុល ប្រសិនបើផ្តល់ជាចំណីក្នុងបរិមាណច្រើនដល់សត្វដែលមិនធ្លាប់ស៊ីស្លឹកដំឡូងមី ។ ត្រូវប្រាកដថា ស្លឹកដំឡូងត្រូវបានហាលឱ្យស្ងួតមុនពេលផ្តល់ជាចំណីដល់សត្វ ។

⇨ **ម្សៅដំឡូងមីៈ** ម្សៅដំឡូងមីគឺជាប្រភពថាមពល ហើយអាចលាយជាមួយកន្ទក់ ឬ ធ្វើជាចំណីបន្ថែមសំរាប់សត្វ ។ វាគឺជាចំណីម្សៅ ហើយមិនអាចឱ្យសត្វស៊ីចំណីនេះតែមួយមុខបានទេ ។ ត្រូវលាយវាជាមួយកន្ទក់ក្នុងបរិមាណស្មើគ្នាដូចជាឧទាហរណ៍ខាងលើ ។ ប៉ុន្តែ ម្សៅដំឡូងមីមានប្រូតេអ៊ីនតិចជាងកន្ទក់ ។

## ចំណីបន្ថែម



- ត្រូវបន្ថែមអំបិល និង កំបោរមួយក្ដាប់ ចូលទៅក្នុង ធុងដែលមានកន្ទក់ចំណុះ ប្រាំលីត្រ



- អាចផ្ដល់អនុផលិតផលជា ចំណីដោយលាយជាមួយកន្ទក់ អំបិល និង កំបោរ





- បេះស្លឹកដំឡូងមី ពីផ្នែកខាងក្រោមនៃដើម
- ហាលស្លឹកដំឡូងមីចំនួនមួយថ្ងៃអោយស្លោក មុនពេលផ្ដល់ជាចំណីសត្វ

ហេហ្វឺ"គំរោងចិញ្ចឹមសត្វ"កម្ពុជា (Heifer Cambodia) បានបើកការិយាល័យតំណាងនៅទីក្រុងភ្នំពេញ នាខែ មករា ឆ្នាំ ១៩៩៩ ។

ហេហ្វឺ"គំរោងចិញ្ចឹមសត្វ"កម្ពុជា កាត់បន្ថយភាពអត់ឃ្លាន ភាពក្រីក្រ និង ស្តារបរិស្ថានឡើងវិញ ដោយផ្តល់ការចិញ្ចឹមសត្វ ការបណ្តុះបណ្តាល និង សេវាកម្មដែលពាក់ព័ន្ធ ទៅឱ្យគ្រួសារកសិករនៅតាមជនបទ ។ ហេហ្វឺ"គំរោងចិញ្ចឹមសត្វ"កម្ពុជា ជួយកសិករឱ្យប្រើប្រាស់ការចិញ្ចឹមសត្វជាសមាសភាគរួមសំរាប់និរន្តរភាពកសិកម្ម និង ការអភិវឌ្ឍន៍ និង ក្នុងការបង្កើនប្រាក់ចំណូលគ្រួសារ ។

ដោយផ្អែកលើមូលដ្ឋានតំលៃ នៃ"ការផ្តល់ជំនួយបន្ត" ហេហ្វឺ"គំរោងចិញ្ចឹមសត្វ"កម្ពុជា បាន នឹង កំពុងដំណើរការការងារជាមួយដៃគូចំនួន ១២ ជាស្ថាប័នរដ្ឋ និង អង្គការក្រៅរដ្ឋាភិបាល ដែលកំពុងគ្រប់គ្រងគំរោងដោយផ្ទាល់នៅក្នុងភូមិចំនួន ៤៨ ក្នុងខេត្តចំនួន ៨ ។ សត្វមេ ត្រូវបានផ្តល់ជូនគ្រួសារក្រីក្រប្រហែល ៤៦៤ គ្រួសារ ហើយកូនសត្វញីលើកទីមួយ ត្រូវបានផ្តល់ជាជំនួយបន្តទៅអោយគ្រួសារក្រីក្រដទៃទៀត ចំនួនប្រហែល ២១១ គ្រួសារ ។

អ្នកចូលរួមបានផ្តល់កូនសត្វ(ញី) មួយ ឬ ច្រើន របស់មេសត្វដែលគេបានទទួលទៅឱ្យគ្រួសារដទៃទៀតនៅក្នុងសហគមន៍ ។ គោលការណ៍នេះ ដែលយើងហៅថា "ការផ្តល់ជំនួយបន្ត" បានបង្កើនសេចក្តីថ្លៃថ្នូរ ដោយធានាថា អ្នកចូលរួមម្នាក់ៗក៏ក្លាយទៅជាម្ចាស់ជំនួយម្នាក់ដែរ ។

HEIFER
INTERNATIONAL
CAMBODIA

ផ្ទះលេខ ៧៧ AE$_0$ ផ្លូវ ៩៥ សង្កាត់បឹងកេងកង ៣ ខណ្ឌចំការមន ក្រុងភ្នំពេញ
Phone/Fax: (855-23) 211 323
Email: hpi.cambodia@online.com.kh